ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......១៣៥៤......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរំលឹកការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៣

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់អចលនទ្រព្យទាំងអស់ នៅរាជធានីភ្នំពេញ និងនៅតាមក្រុងនីមួយៗនៃខេត្តទាំងអស់ មេត្តាជ្រាបថា ពន្ធលើអចលនទ្រព្យបានអនុវត្តប្រមូលពន្ធចាប់ពីដើមឆ្នាំ និងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ខាងមុខនេះ ដោយអនុលោមតាមកថាខ័ណ្ឌ ៣ ចំណុច I នៃសារាចរណែនាំលេខ ០១៥ សហវ.អពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ រហូតមកដល់ពេលនេះអគ្គនាយកដ្ឋានពន្ធដារបានសង្កេតឃើញថា មានម្ចាស់អចលនទ្រព្យភាគតិចបានអញ្ជើញមកប្រកាសបង់ពន្ធតាមសារាចរណែនាំខាងលើនេះ ។

ដើម្បីជំរុញឱ្យការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៣នេះ បានទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារសូមក្រើនរំលឹកដល់ម្ចាស់អចលនទ្រព្យទាំងអស់ ដែលពុំទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យ មេត្តារួសរាន់មកប្រកាសបង់ពន្ធឱ្យបានទាន់ពេលវេលា នាមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣ ដោយចៀងវាងនូវការប្រជ្រៀតគ្នានៅថ្ងៃជិតផុតកំណត់ នាំឱ្យខកខានពុំបានបំពេញកាតព្វកិច្ចបង់ពន្ធនេះ ។

ម្ចាស់អចលនទ្រព្យអាចអញ្ជើញទៅបង់ពន្ធនេះនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬសាខាធនាគារ កាណាឌីយ៉ា ក.អ ដែលអចលនទ្រព្យនោះស្ថិតនៅ ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់អចលនទ្រព្យទាំងអស់មានស្មារតីគោរពច្បាប់ និងអញ្ជើញមកប្រកាសបង់ពន្ធទាន់តាមកាលកំណត់ខាងលើ ជាពុំខាន ។

ប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល